ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
=======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
=======

**មាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរពីប្រទេសម៉ាឡេស៊ី**
**និងការឧបត្ថម្ភដល់ពលករខ្មែររងរបួសនៅប្រទេសថៃ**

* * * * * *

១- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានអន្តរាគមន៍ជួយដោះស្រាយបញ្ហារបស់ពលករ-ពលការិនីខ្មែរ**៣នាក់** និងរៀបចំមាតុភូមិនិវត្តន៍របស់ពួកគេមកកម្ពុជាវិញ៖

- ពលការិនី ឈ្មោះ **ឡ.គ** អាយុ៣៥ឆ្នាំ មានស្រុកកំណើតនៅខេត្តត្បូងឃ្មុំ ត្រូវបានមេខ្យល់បោកបញ្ឆោតយកទៅធ្វើការជាអ្នកបោសសំអាតនៅម៉ាឡេស៊ី ពីថ្ងៃ១៤ ខែតុលា ឆ្នាំ២០១៦។ ដោយធ្វើការលំបាក ពលការិនីបានទៅស្ថានទូត នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ស្នើសុំជួយអោយបានត្រឡប់មកកម្ពុជាវិញ។ តាមសំណូមពររបស់ស្ថានទូត ថៅកែរបស់ពលការិនី បានយល់ព្រមប្រគល់លិខិតឆ្លងដែនដល់ពលការិនីវិញ។ ដោយសារពលការិនីខ្វះខាតថវិកា ស្ថានទូតបានឧបត្ថម្ភសំបុត្រយន្តហោះសម្រាប់ការធ្វើដំណើរមកកម្ពុជា។

- ពលការិនី ឈ្មោះ **ប.ស** អាយុ២៥ឆ្នាំ មានស្រុកកំណើតនៅខេត្តបាត់ដំបង បានទៅធ្វើការជាអ្នកបោសសំអាតនៅម៉ាឡេស៊ី ពីថ្ងៃ០២ ខែកក្កដា ឆ្នាំ២០១៥ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជាឈ្មោះAT។ ដោយធ្វើការលំបាក ពលការិនីបានទៅស្ថានទូតនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្នើជួយទាមទារប្រាក់ខែដែលនៅសល់ និងជួយអោយបានត្រឡប់មកកម្ពុជាវិញ។ ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត ថៅកែរបស់ពលការិនី បានយល់ព្រមប្រគល់លិខិតឆ្លងដែន និងប្រាក់ខែដែលនៅសល់ ដល់ពលការិនីវិញ។

ពលការិនី **ឡ.គ** និងពលការិនី **ប.ស** នឹងមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**០៩** ខែ **វិច្ឆិកា** ឆ្នាំ**២០១៦** វេលាម៉ោង**០៧:៥០**នាទីព្រឹក តាមជើងយន្តហោះលេខ AK536 ។

- ពលករ ឈ្មោះ **ង.រ** អាយុ៣១ឆ្នាំ មានស្រុកកំណើតនៅខេត្តកណ្តាល បានជាប់ឃុំនៅពន្ធនាគារ Semenyih ក្នុងរដ្ឋ Selangor ប្រទេសម៉ាឡេស៊ី ពីខែកុម្ភៈ ឆ្នាំ២០១៥ ដោយសាររស់នៅ និងធ្វើការខុសច្បាប់ ហើយពុំមានលិខិតឆ្លងដែន។ បច្ចុប្បន្ន ពលករបានរួចទោស ហើយស្ថានទូតបានឧបត្ថម្ភសំបុត្រយន្តហោះសម្រាប់ការធ្វើដំណើរមកកម្ពុជាវិញ។

ពលករ **ង.រ** នឹងមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី០៨ ខែ **វិច្ឆិកា** ឆ្នាំ**២០១៦** វេលាម៉ោង**១៦:០០**នាទី តាមជើងយន្តហោះលេខ AK534 ។

២- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ បានចាត់មន្ត្រីស្ថានទូតទៅសួរសុខទុក្ខ និងឧបត្ថម្ភថវិការចំនួន**៧.៥០០បាត** ដល់ពលករខ្មែរ ឈ្មោះ **ច.រមហ** អាយុ២២ឆ្នាំ មកពីខេត្តបន្ទាយមានជ័យ ដែលត្រូវបានពលករមីយ៉ាន់ម៉ារ ចាក់នឹងកាំបិតចំទ្រូងខាងឆ្វេង ហើយកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ ពលកររូបនេះ បានចូលមកប្រទេសថៃ ដោយពុំមានឯកសារអ្វីទាំងអស់ កាលពីខែមេសា ឆ្នាំ២០១៦ ហើយធ្វើការខុសច្បាប់ជាមួយក្រុមហ៊ុនប្រមូលសំរាមមួយនៅជាយក្រុងបាងកក។

ពលករងគ្រោះត្រូវបានសង្គ្រោះបឋមនៅមន្ទីរពេទ្យមួយក្នុងខេត្ត**នន្ទបុរី** (Nonthaburi) ដោយត្រូវចំណាយលើថ្លៃព្យាបាលចំនួន១២ម៉ឺនបាត។ តាមសំណើរបស់ស្ថានទូត មន្ទីរពេទ្យបានយល់ព្រមឲ្យសាមីខ្លួនបង់ត្រឹមចំនួន៦ម៉ឺនបាតប៉ុណ្ណោះ និងអោយចុះកិច្ចសន្យាសងប្រាក់ដែលខ្វះ នៅពេលណាមានថវិកា (តំណាងមន្ទីរពេទ្យបញ្ជាក់ថា កិច្ចសន្យានេះ គ្រាន់តែជាការបង្គ្រប់កិច្ចប៉ុណ្ណោះ ដោយមន្ទីរពេទ្យមិនបង្ខំទារប្រាក់នៅខ្វះនេះឡើយ)។ នៅថ្ងៃទី៤ ខែ វិច្ឆិកា ពលកររងគ្រោះ ត្រូវបានបញ្ជូនបន្តទៅវះកាត់នៅមន្ទីរពេទ្យមួយទៀតក្នុងទីក្រុងបាងកក។

ក្រៅពីជម្រុញដំណើរការកាត់ទោសជនល្មើសទៅតាមផ្លូវច្បាប់ ស្ថានទូតកំពុងទាមទារអោយនិយោជករបស់ពលកររងគ្រោះ ជួយឧបត្ថម្ភដល់ការព្យាបាលរបួសរបស់ពលកររូបនេះផងដែរ៕

ភ្នំពេញ, ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ